00634897

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារ/No: D427/1/26

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់*
*ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧៥)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 01 / 2011
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
អៀង សារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ឡោ ជុនធី
គង់ ពិសី

**សហមេធាវីការពារជនជាប់ចោទ**
អាង ឧត្តម
Michael G. KARNAVAS

00634898

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥)

លេខ/No: D427/1/26

ហុង គីមសួន
យ៉ុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Elizabeth RABESANRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUDZINSKY
DELAHAIE Annie
Fabienne TRUSSES-NAPROUS
ស៊ីន សុវ៉ន
វ៉េន ពៅ
BEAUDOIN Patrick
GUIRAUD Marie
LYMA NGUYEN
ជេត វណ្ណលី
DESFORGES Laure
DURAND Isabelle
GAUTRY Francoise
MARTINEAU Christine
Pascal AUBOIN
Ferdinand DJAMMEN- Nzepa
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
ពេជ អង្គ

<u>សហចៅក្រមស៊ើបអង្កេត</u>

យូ ប៊ុនឡេង

Siegfried BLUNK

*E.C.C.C * C.E.T.C* PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៧៥)

**លេខ/No: D427/1/26**

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ [របស់សហចៅក្រមស៊ើបអង្កេត]" ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")[១] ដែលបានដាក់កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។

បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូន ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

<u>មូលដ្ឋានទីមួយ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា *គោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ (ne bis in idem)* មិនរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននោះទេ[២]។

<u>មូលដ្ឋានទីពីរ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស លោក អៀង សារី មិនរារាំងការចោទប្រកាន់លោក អៀង សារី នាពេលបច្ចុប្បន្ននោះទេ[៣]។

<u>មូលដ្ឋានទីបី</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ព្រោះយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តលើបទល្មើសអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ ដោយហេតុថា ការធ្វើដូច្នេះ នឹងរំលោភបំពានទៅលើ*គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)*[៤]។

<u>មូលដ្ឋានទីបួន</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្វីបើមានអាជ្ញាយុកាលនៃបទល្មើសក៏ដោយ[៥]។

---

[១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6 ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")។

[២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២១ ដល់៤១។

[៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៤២ ដល់១០២។

[៤] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ១០៣ ដល់១៣៥។

[៥] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ១៣៦ ដល់១៣៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

<u>មូលដ្ឋានទីប្រាំ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការដើម្បីអនុវត្តមាត្រា ៣ថ្មី (បទល្មើសជាតិ)[៦]។

<u>មូលដ្ឋានទីប្រាំមួយ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បើសិនជារកឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៧]។

<u>មូលដ្ឋានទីប្រាំពីរ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បើសិនជារកឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៨]។

<u>មូលដ្ឋានទីប្រាំបី</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ បើសិនជារកឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[៩]។

<u>មូលដ្ឋានទីប្រាំបួន</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម[១០]។

<u>មូលដ្ឋានទីដប់</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ ចំពោះការអនុវត្តការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ[១១]។

<u>មូលដ្ឋានទីដប់មួយ</u>៖ ក.ស.ច.ស មានការភ័ន្តច្រឡំអង្គច្បាប់ដោយយល់ឃើញថា អ.វ.ត.ក មានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ និងការអនុវត្តនូវការទទួលខុសត្រូវរបស់ថ្នាក់លើ បើសិនជារកឃើញថាអាចអនុវត្តបាននៅ អ.វ.ត.ក[១២]។

អង្គបុរេជំនុំជម្រះបានសម្រេចជាស្ថាពរលើបណ្តឹងឧទ្ធរណ៍ ដូចដែលអង្គបុរេជំនុំជម្រះប្រកាសនៅពេលនេះ។ ការចេញសំអាងហេតុសម្រាប់គាំទ្រសេចក្តីសម្រេចនេះ នឹងធ្វើទៅតាមពេលវេលាសមស្រប។

---

[៦] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ១៣៨ ដល់១៧៩។

[៧] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ១៨០ ដល់១៨៣។

[៨] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ១៨៤ ដល់២៣១។

[៩] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៣២ ដល់២៤៨។

[១០] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៤៩ ដល់២៧២។

[១១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៧៣ ដល់២៨២។

[១២] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៨៣ ដល់៣២៤។

00634901



## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២. មូលដ្ឋានទីមួយ ទីពីរ ទីបី ទីប្រាំ ទីប្រាំពីរ (មួយផ្នែក) និងទីដប់មួយ (មួយផ្នែក) អាចទទួលយកបាន។ មូលដ្ឋានដែលនៅសល់ផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ។

៣. មូលដ្ឋានទីមួយ ត្រូវបានបដិសេធ។

៤. មូលដ្ឋានទីពីរ ត្រូវបានបដិសេធ។

៥. មូលដ្ឋានទីបី ត្រូវបានបដិសេធ។

៦. មូលដ្ឋានទីប្រាំ ត្រូវបានបដិសេធ។

៧. មូលដ្ឋានទីប្រាំពីរ ដូចដែលវាអាចទទួលយកបាន ត្រូវបានអនុញ្ញាតចំពោះផ្នែកខ្លះ រីឯផ្នែកផ្សេងពីនេះត្រូវបានបដិសេធ។

១. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានពុំបានធ្វើការពិចារណាថា ក្នុងអំឡុងពេលយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តម្រូវឱ្យមានចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ “អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ” ត្រូវបានបូកបន្ថែមជាលក្ខខណ្ឌតម្រូវ “ធាតុផ្សំ” មួយនៅក្នុងផ្នែកទីIV(ក) ជំពូកបី នៃដីកាដំណោះស្រាយ។

២. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ក្នុងរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត

នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

៨. មូលដ្ឋានទីដប់មួយ ដូចដែលវាអាចទទួលយកបាន ត្រូវបានបដិសេធ។

៩. ផ្សេងពីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

១០. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឲ្យបញ្ជូនខ្លួនទៅជំនុំជម្រះ ដូចបានចែងនៅក្នុងដីកាដំណោះស្រាយ ដែលត្រូវអានព្រមគ្នាជាមួយនឹងសាលដីកានេះ។

១១. ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ត្រូវបានបង្គាប់ឲ្យបន្តរហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន័យ ថុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គីមសាន**